United Nations Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

# សេចក្តីប្រកាសព័ត៌មានរួម

**១១ មករា ២០១១**

**សំរាប់ចេញផ្សាយបន្ទាប់**

## អង្គការសហប្រជាជាតិសូមស្វាគមន៍ការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសិទ្ធិស្ត្រី ក្នុងឱកាសដែលកម្ពុជាបានក្លាយជាប្រទេសទី១០០ ដែលផ្តល់សច្ចាប័នលើនីតិវិធីថ្មីនេះ

ភ្នំពេញ កម្ពុជា ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា(ការិយាល័យ OHCHR) និង អង្គការសហប្រជាជាតិស្តីពីស្ត្រី (UN WOMEN) សូមស្វាគមន៍ការផ្តល់សច្ចាប័នរបស់កម្ពុជាលើពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១១។ តំណាងរបស់ UN WOMEN លោក Wenny Kusuma បានប្រសាសន៍ថា "ការិយាល័យ OHCHR និង UN WOMEN សូមអបអរសាទរដល់រាជរដ្ឋាភិបាលចំពោះ ការបង្ហាញឲ្យឃើញជាក់ស្តែង នូវការប្តេជ្ញាចិត្តជាបន្តដើម្បីការពារ និង លើកស្ទួយសិទ្ធិមនុស្ស ជាពិសេស សិទ្ធិស្ត្រី"។ "ការទទួលយករបស់រដ្ឋាភិបាលនូវនីតិវិធីបណ្តឹងរបស់CEDAW បង្ហាញថារដ្ឋាភិបាលអនុវត្តន៍កាតព្វកិច្ចអន្តរជាតិរបស់ខ្លួនយ៉ាងហ្មត់ចត់ ក្នុងការធានាថា ការដោះស្រាយពិតប្រាកដ ទាន់ពេលវេលា និងអាចអនុវត្តន៍បានពិតជាមានសំរាប់ការរំលោភសិទ្ធិស្ត្រី" ។

តារយៈការផ្តល់សច្ចាប័នពិធីសារបន្ថែមលើអនុសញ្ញាCEDAW បច្ចុប្បន្ននេះ កម្ពុជាអនុញ្ញាតឲ្យ ឯកត្តបុគ្គល និងក្រុមផ្សេងៗដែលយល់ថាសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិស្ត្រី ។ គណៈកម្មាធិការនេះ អាចពិនិត្យលើ ពាក្យបណ្តឹងទាំងនេះនៅពេលដែលការដោះស្រាយបណ្តឹងនេះត្រូវបានប្រើប្រាស់អស់លទ្ធភាពនៅ កម្ពុជា ។ បន្ថែមលើនេះទៀតគណៈកម្មាធិការនេះអាចផ្តួចផ្តើមការស៊ើបអង្កេតដោយស្វយ័ត ទៅលើការរំលោភសិទ្ធិស្ត្រីធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ។ ក្នុងនាមជារដ្ឋទី១០០ ដែលផ្តល់សច្ចាប័ន លើពិធីសារបន្ថែមនេះ កម្ពុជាក៏ក្លាយជាប្រទេសនាំមុខគេមួយផងដែរ នៅអាស៊ីអគ្នេយ៍ក្នុងការផ្តល់ វេទិកាអន្តរជាតិសំរាប់ដោះស្រាយបណ្តឹងផ្សេងៗ ដែលមានហ្វីលីពីន និង ថៃ ជាប្រទេសពីរ ទៀតក្នុងសមាគមអាស៊ាន ដែលបានចាត់វិធានការនេះ។

តំណាងការិយាល័យ OHCHR លោក គ្រីស្តូហ្វ ប៉េស្វ៊ មានប្រសាសន៍ថា "យន្តការដោះស្រាយបណ្តឹងដែលសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិបានបង្កើតឡើង ផ្តល់អត្ថន័យជាក់ច្បាស់ដល់សិទ្ធិស្ត្រី តាមរយៈការផ្តល់ឲ្យឯកត្តបុគ្គលនូវមធ្យោបាយបន្ថែមក្នុងការដោះស្រាយត្រឹមត្រូវតាមផ្លូវច្បាប់ចំពោះការរំលោភសិទ្ធិរបស់ខ្លួនក្នុងជីវិតរស់នៅ"។ " រដ្ឋាភិបាលកម្ពុជាទទួលបានការអបអរសាទរចំពោះ ភាពជឿនលឿននេះ ។ យើងសង្ឃឹមថា កម្ពុជានឹងកសាងបន្ថែមពីលើចំណុចចាប់ផ្តើមនេះ ហើយផ្តល់សច្ចាប័នលើយន្តការដោះស្រាយបណ្តឹងទាំងឡាយក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សឯទៀត" ។

យន្តការបណ្តឹងជាបុគ្គលផ្សេងទៀត បើកសំរាប់ប្រទេស កម្ពុជាទទួលយក មានជាអាទិ៍ នៅក្រោមអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។ យន្តការដូចនេះ ក៏មានផងដែរ ក្រោមអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ ហើយកម្ពុជាអាចទទួលយក នៅពេលដែលកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាទាំងនេះរួច ។

For further information please contact Zoe Latumbo at 012790178